**ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល** បានអញ្ជើញពិនិត្យវឌ្ឍនភាព និងសួរសុខទុក្ខ សំណេះសំណាល ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃ**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

=========

រាជធានីភ្នំពេញ៖ ព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល** និងថ្នាក់ដឹកនាំក្រសួងសុខាភិបាល បានអញ្ជើញចុះពិនិត្យវឌ្ឍន ភាព និងសួរសុខទុក្ខ សំណេះសំណាលថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិក នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើ ស្បែក និងកាមរោគ ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងសុខាភិបាល និងប្រធានមជ្ឈមណ្ឌលជាតិ។

**ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី** បានចុះពិនិត្យការផ្តល់សេវាផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ ក្នុងការស្វែងយល់ពីការប្រើប្រាស់ម៉ាស៊ីនធ្វើតេស្តមេរោគអេដស៍ក្នុងឈាម (រាប់ចំនួនមេរោគ) រយៈពេលនៃការធ្វើការតេស្ត និងបច្ចេកទេសប្រើប្រាស់។ **ឯកឧត្តមរដ្ឋមន្ត្រី** បានណែនាំការប្រើប្រាស់ម៉ាស៊ីន ដោយត្រូវចូលរួមថែទាំឱ្យបានត្រឹមត្រូវស្រប តាមលក្ខណៈបច្ចេកទេស និងមានឯកសារកិច្ចសន្យាឱ្យបានច្បាស់លាស់ ចៀសវាងមានបញ្ហាបច្ចេកទេសណាមួយពិបាក ស្វែង រកប្រភពព័ត៌មាននិងការទទួលខុសត្រូវ។

ក្នុងឱកាសនោះដែរ **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋន្ត្រី** បានជួបសួរសុខទុក្ខប្រជាពលរដ្ឋ ដែលអញ្ជើញមកទទួលសេវានៅគ្លីនិក នៃ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងបំណងស្វែងយល់ការបម្រើសេវារបស់មន្ត្រីសុខាភិបាល ទាំងទទួលបដិសណ្ឋាកិច្ច បច្ចេកទេសព្យាបាល និងក្រមសីលធម៌វិជ្ជាជីវៈ។ ឯកឧត្តមក៏បានណែនាំដល់ប្រជាពលរដ្ឋដែលមកទទួលសេវា ដោយត្រូវថែទាំសុខភាពរបស់ខ្លួនឱ្យបានល្អ ទាំងសុខភាពផ្លូវ កាយ និងជាពិសេសសុខភាពផ្លូវចិត្ត ព្រមទាំងអញ្ជើញមកជួប ឬពិគ្រោះទៀងទាត់ជាមួយក្រុមគ្រូពេទ្យតាមពេលវេលាកំណត់។

ខណៈជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកសុខាភិបាលនៃមជ្ឈមណ្ឌលជាតិ **ឯកឧត្តមសាស្ត្រាចារ្យ** បានរំលឹកលើកឡើងថា មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ បានដើរតួ សំខាន់ ក្នុងវិស័យសុខាភិបាលរបស់ប្រទេសកម្ពុជា ទាំងកម្រិតជាតិ និងអន្តរជាតិ ដែលក្នុងឆ្នាំ ២០២៣ ករណីឆ្លងថ្មីនៃមេ
រោគអេដស៍ មានប្រមាណជា ៣ ទៅ ៤ នាក់/ថ្ងៃ។ **ឯកឧត្តមសាស្ត្រាចារ្យ** ជម្រុញលើកទឹកចិត្ត ឱ្យមជ្ឈមណ្ឌលជាតិ ពង្រឹងកិច្ច សហប្រតិការជាមួយដៃគូអភិវឌ្ឍ ដើម្បីជម្រុញការបង្ការទប់ស្កាត់ការឆ្លងថ្មីនៃមេរោគបន្ថែមទៀត ចៀសវាងនូវការការឆ្លង រាល
ដាលខ្លាំង នឹងនាំមកនូវផលវិបាកធ្ងន់ធ្ងរដល់សង្គម ដូចជា បញ្ហាមរណៈភាព បន្សល់នូវក្មេងកំព្រា ឆ្លងទៅជំនាន់ក្រោយៗដែល ជាបញ្ហាគម្រាមកំហែងដល់សុខភាពសាធារណៈនៅប្រទេសកម្ពុជាយើង។

ក្នុងនោះដែរ **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍គន្លឹះមួយចំនួន ដើម្បីការអនុវត្តការងារប្រចាំថ្ងៃ ឱ្យមានប្រសិទ្ធភាពបន្ថែមទៀតដូចជា៖

- សូមប្តេជ្ញាចិត្តក្នុងការកាត់បន្ថយអត្រានៃការឆ្លងជំងឺអេដស៍

- លើកទឹកចិត្តក្នុងការផ្តល់ការបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយការ យកចិត្តទុកដាក់
- ត្រៀមលក្ខណៈបង្កើនការផ្សព្វផ្សាយ និងរំលេចសកម្មភាពថ្មីៗ អំពីការអប់រំសុខភាពពីជំងឺអេដស៍ ក្នុងពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ខាងមុខនេះ
- ផ្សារភ្ជាប់យុទ្ធសាស្ត្រជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- សូមប្រែក្លាយការណែនាំ ទៅជាសកម្មភាព។

ជាទីបញ្ចប់

**ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី**

បានលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិក ត្រូវខិតខំពង្រឹងសមត្ថភាពបន្ថែមទៀត តាមរយៈការបណ្តុះបណ្តាលផ្នែកជំនាញ និងបច្ចេកទេស ព្រមទាំងចែករំលែកចំណេះដឹង រវាងគ្នានិងគ្នា ចេះស្រឡាញ់រាប់ អានគ្នា សាមគ្គីភាពកាន់តែជាធ្លុងមួយ និងចែករំលែកបទពិសោធន៍គ្នា ដើម្បីបន្តបង្កើនសមត្ថភាព និងប្រសិទ្ធភាពការងារ ថែមទៀត។